**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៦៨៣.....សហវ.ឧបក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
## សម្រាប់ឆ្នាំ២០១៥

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥ ត្រូវប្រមូលចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។

**ប្រការ ២.-** ម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥ នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារ កាណាឌីយ៉ា ក.អ កម្ពុជា ឬនៅធនាគារ អេស៊ីលីដា ភីអិលស៊ី។

**ប្រការ ៣.-** ដើម្បីបង់ពន្ធមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥ ម្ចាស់យានយន្តត្រូវភ្ជាប់មកជាមួយនូវ ÷

ក- បណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដោយមិនចាំបាច់ដាក់លិខិតប្រកាសបង់ពន្ធ។ ក្នុងករណីបាត់បណ្ណនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំបោះពុម្ពបណ្ណបង់ពន្ធ សាជាថ្មី នៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅអគ្គនាយកដ្ឋានពន្ធដារ ដោយត្រូវបង់ថ្លៃសេវាធ្វើបណ្ណចំនួន ៥ ០០០ រៀល ឬ

ខ- ឯកសារបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ ដោយត្រូវដាក់លិខិតប្រកាសបង់ពន្ធចំនួន ០២ សន្លឹក តាមទម្រង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងករណីបាត់ឯកសារបង់ពន្ធនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ នៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីប្រើប្រាស់ក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៥។ ការដាក់លិខិតប្រកាសបង់ពន្ធនេះ ត្រូវភ្ជាប់មកជាមួយឯកសារដូចខាងក្រោម ÷

- បណ្ណសម្គាល់យានយន្ត ឬ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន ឬ
- បង្កាន់ដៃបង់ពន្ធនាំចូល ឬ
- លិខិតបញ្ជាក់ការប្រើប្រាស់យានយន្តចេញដោយឃុំ-សង្កាត់ ចំពោះយានយន្តកែច្នៃក្នុងស្រុក និង
- អត្តសញ្ញាណបណ្ណសម្គាល់ខ្លួនរបស់ម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់សំបុត្រកំណើត ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន។

គ- ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទដែលទើបមកប្រកាសបង់ពន្ធលើកដំបូង ត្រូវដាក់លិខិតប្រកាសបង់ពន្ធចំនួន ០២ សន្លឹក តាមទម្រង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ និងភ្ជាប់មកជាមួយនូវឯកសារដូចមានចែងក្នុងចំណុច “ខ” នៃប្រការនេះ។

ដើម្បីមានភាពងាយស្រួលក្នុងការប្រកាសបង់ពន្ធប្រភេទនេះនៅឆ្នាំបន្តបន្ទាប់ខាងមុខ ម្ចាស់យានជំនិះអាចស្នើសុំធ្វើបណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដោយគ្រាន់តែគូសក្នុងប្រអប់ដូចមានបង្ហាញក្នុងលិខិតប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥។ ការស្នើសុំបោះពុម្ពបណ្ណនេះ ត្រូវបង់ថ្លៃសេវា ចំនួន ៥ ០០០ រៀល។

ឃ- ចំពោះរទេះចក្រយានយន្ត និងត្រីចក្រយានយន្តដែលបំពាក់ដោយម៉ាស៊ីនម៉ូតូ មិនចាំបាច់ដាក់លិខិតប្រកាសបង់ពន្ធ និងមិនចាំបាច់ភ្ជាប់មកជាមួយនូវឯកសារផ្សេងៗឡើយ។

**ប្រការ ៤.-** ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទទាំងឡាយ ដែលមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ នៅក្នុងឆ្នាំ២០១៤ ហើយមានបង្កាន់ដៃបង់ពន្ធនាំចូលមុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ ឬមិនមានបង្កាន់ដៃបង់ពន្ធនាំចូល ត្រូវបង់ប្រាក់ពន្ធ និងប្រាក់ពិន័យសម្រាប់បណ្តាឆ្នាំដែលបានខកខានមិនបានបង់ពន្ធកន្លងមក ឱ្យបានរួចរាល់ជាមុនសិន ទើបអនុញ្ញាតឱ្យប្រកាសបង់ពន្ធសម្រាប់ឆ្នាំ២០១៥។

**ប្រការ ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ទៅតាមប្រភេទនីមួយៗ ដោយមិនគិតថាជាកម្មសិទ្ធិរបស់រដ្ឋ ឬឯកជនឡើយ ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ រួមមាន ÷

- ឧបសម្ព័ន្ធ I ចែងអំពីការកំណត់រូបភាព និងលក្ខណៈសម្គាល់លតាបត្របង់ពន្ធ
- ឧបសម្ព័ន្ធ II និងឧបសម្ព័ន្ធ III ចែងអំពីការកំណត់ប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ។

**ប្រការ ៦.-** ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបានលើកលែងចំពោះ ÷

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យជាកម្មសិទ្ធិរបស់រដ្ឋ
- យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់កិច្ចការការពារជាតិ ជាមធ្យោបាយប្រើប្រាស់ដឹកជញ្ជូនសម្ភារទ័ព ឬដឹកជញ្ជូនកងទ័ព ក៏ដូចជាសម្រាប់កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដូចមានចែងក្នុងមាត្រា ១១ និងមាត្រា ១២ នៃអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ និងយានយន្តដែលពាក់ផ្លាកលេខ ខ.ម ឬ ន.ប ជាផ្លូវការ ដែលមានការទទួលស្គាល់ និងបញ្ជាក់ពីក្រសួងការពារជាតិ ឬក្រសួងមហាផ្ទៃ
- យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូត ឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

ក្រសួង-ស្ថាប័ន ឬអង្គភាព ដែលជាអាណាព្យាបាល ឬជាម្ចាស់កម្មសិទ្ធិនៃយានយន្តដូចមានចែងនៅក្នុងប្រការនេះ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបាននូវលតាបត្របង់ពន្ធ (ពន្ធជាបន្ទុករបស់រដ្ឋ) ដោយភ្ជាប់មកជាមួយនូវបញ្ជីសារពើភណ្ឌយានយន្តរបស់ក្រសួង-ស្ថាប័ន ឬអង្គភាពដែលបានស្នើសុំនោះ។

**ប្រការ ៧.-** ក្រោយពេលបង់ពន្ធរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ត្រូវទទួលបានលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធមួយសន្លឹក/បង្កាន់ដៃបង់ពន្ធមួយសន្លឹក និងលតាបត្រសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយសន្លឹក។ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ/បង្កាន់ដៃបង់ពន្ធនេះ ត្រូវរក្សាទុកជាប់នឹងយានយន្ត សម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច និងជាឯកសារសម្រាប់ប្រកាសបង់ពន្ធនៅឆ្នាំបន្ទាប់។

**ប្រការ ៨.-** សម្រាប់ឆ្នាំ២០១៥ លតាបត្របង់ពន្ធដែលត្រូវបិទភ្ជាប់នឹងយានយន្ត មានរូបភាពនិងលក្ខណៈសម្គាល់ ដូចមានចែងក្នុងឧបសម្ព័ន្ធ I ភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ៩.-** រថយន្តដឹកទំនិញធុនតូចដែលមានទ្វារ៤ (PICK UP) និងរថយន្តកែច្នៃផ្សេងទៀត ÷

- ចាត់ទុកជារថយន្តទេសចរណ៍ ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតដល់ ០៧ឆ្នាំ ត្រូវបង់ពន្ធតាមទំហំស៊ីឡាំង ដូចមានចែងក្នុងឧបសម្ព័ន្ធ III ភ្ជាប់ជាមួយប្រកាសនេះ។ ចាត់ទុកជារថយន្តដឹកទំនិញធុនតូច មានទម្ងន់សរុបដល់ ៣តោន ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតលើសពី ០៧ឆ្នាំ ត្រូវបង់ពន្ធតាមទម្ងន់ ផ្ទុក ដូចមានចែងក្នុងឧបសម្ព័ន្ធ II
- ចំពោះរថយន្តកែច្នៃផ្សេងទៀត ត្រូវចាត់ទុកជារថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង ដែលត្រូវកំណត់ដោយផ្អែកតាមទម្ងន់សរុប រួមមាន ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ-មនុស្ស) ដូចមានចែងក្នុងឧបសម្ព័ន្ធ II។

**ប្រការ ១០.-** ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ តទៅ អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំយន្តការត្រួតពិនិត្យការបង់ពន្ធ និងផាកពិន័យចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះទាំងឡាយណា ដែលមិនបានប្រកាសបង់ពន្ធតាមការកំណត់ខាងលើ។

**ប្រការ ១១.-** នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្ត ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១៥

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u> ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អង្គភាពក្រោមឱវាទកសហវ "ដើម្បីអនុវត្ត"
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ...................សហវ

# ឧបសម្ព័ន្ធ I

## ស្ដីពី

## ការកំណត់រូបភាព និងលក្ខណៈសម្គាល់បណ្ណបង់ពន្ធ

ភ្ជាប់ជាមួយប្រកាសលេខ ៦៨៣ សហវ.ប្រក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បណ្ណបង់ពន្ធដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៥ មាន រូបភាព និងលក្ខណៈសម្គាល់ ដូចខាងក្រោម ÷

**១. បណ្ណរាងចតុកោណកែង (សម្រាប់ប្រើប្រាស់លើរថយន្ត និងត្រាក់ទ័រ)** ÷ មាត្រដ្ឋាន (91,64mm x 89,26mm)

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" "**បណ្ណបង់ពន្ធរថយន្ត**" ឬ "**បណ្ណបង់ពន្ធត្រាក់ទ័រ**"។ នៅចំកណ្ដាលបណ្ណរំលេចរូប ប្រាសាទអង្គរវត្ត រាងជាស្រមោល ផ្នែកកណ្ដាលស្ដាំដៃបណ្ណមានបោះពុម្ព **Hologram Gold Logo** របស់អគ្គនាយកដ្ឋានពន្ធដារ និងនៅផ្នែកខាងក្រោមនៃបណ្ណមានតម្លៃបណ្ណ ឆ្នាំបង់ពន្ធ និង **Barcode** ដែលមានលេខរៀងបណ្ណ និងលេខ **Barcode** ដូចគ្នា។ ផ្ទៃខាងក្រោយបណ្ណមានបង្កប់បន្ទះ **Chip** សុវត្ថិភាព **RFID**។

**បណ្ណរាងចតុកោណកែងនេះមាន ១៧ពណ៌ គឺ ÷**

ក. សម្រាប់ត្រាក់ទ័រ ÷

- បណ្ណពណ៌ត្រាវរំលេចលឿងខ្ចី តម្លៃ ៣០ ០០០រៀល មានកម្លាំង ៣៥សេះ
- បណ្ណពណ៌ត្រាវរំលេចស្លាទុំ តម្លៃ ៤០ ០០០រៀល មានកម្លាំងលើសពី ៣៥សេះ ដល់ ៦៥សេះ
- បណ្ណពណ៌ត្រាវរំលេចលឿង តម្លៃ ៥០ ០០០រៀល មានកម្លាំងលើសពី ៦៥សេះ ឡើងទៅ

ខ. សម្រាប់រថយន្ត ÷

- បណ្ណពណ៌ត្រាវរំលេចត្រួយចេក តម្លៃ ៨០ ០០០រៀល ប្រើសម្រាប់ ÷
  - + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១ ៥០០ស.ម$^{៣}$ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ
- បណ្ណពណ៌ត្រាវរំលេចក្រហម តម្លៃ ១០០ ០០០រៀល ប្រើសម្រាប់ ÷
  - + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១ ៥០០ស.ម$^{៣}$ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ
  - + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ១ ៥០០ស.ម$^{៣}$ ដល់ ២ ០០០ស.ម$^{៣}$ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- បណ្ណពណ៌ត្រាវរំលេចផ្ទៃមេឃ តម្លៃ ១៥០ ០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១ ៥០០ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
  + រថយន្តទេសចរណ៍ ទំហំស៊ីឡាំងលើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ
  + រថយន្តដឹកទំនិញដល់ ៣តោន
  + រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី
- បណ្ណពណ៌ត្រាវរំលេចឈាមជ្រូក តម្លៃ ២០០ ០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
  + រថយន្តដឹកអ្នកដំណើរចុះមធ្យមមានកៅអីពី ១៦កៅអី ដល់ ២៥កៅអី
- បណ្ណពណ៌ត្រាវរំលេចបៃតងចាស់ តម្លៃ ២៥០ ០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ
  + រថយន្តដឹកអ្នកដំណើរចុះធំមានកៅអីលើសពី ២៥កៅអី
  + រថយន្តដឹកទំនិញលើសពី ៣តោន ដល់ ១០តោន
  + រ៉ឺម៉កសណ្តោងដល់ ១០តោន
- បណ្ណពណ៌ត្រាវរំលេចស្វាយ តម្លៃ ៤០០ ០០០រៀល ប្រើសម្រាប់រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ
- បណ្ណពណ៌ត្រាវរំលេចទឹកប៊ិច តម្លៃ ៤៥០ ០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តដឹកទំនិញលើសពី ១០តោន ដល់ ២០តោន
  + រ៉ឺម៉កសណ្តោងលើសពី ១០តោន ដល់ ២០តោន
- បណ្ណពណ៌ត្រាវរំលេចក្រហម និងផ្ទៃមេឃ តម្លៃ ៦០០ ០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ៩០០ ស.ម³ ដល់ ៤ ០០០ ស.ម³ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ
- បណ្ណពណ៌ត្រាវរំលេចលឿង និងស្លាទុំ តម្លៃ ៧៥០ ០០០រៀល ប្រើសម្រាប់ ÷
  + រថយន្តដឹកទំនិញលើសពី ២០តោន
  + រ៉ឺម៉កសណ្តោងលើសពី ២០តោន
- បណ្ណពណ៌ត្រាវរំលេចលឿងខ្ចី និងផ្ទៃមេឃ តម្លៃ ៨០០ ០០០រៀល ប្រើសម្រាប់រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤ ០០០ស.ម³ គិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ
- បណ្ណពណ៌ត្រាវរំលេចឈាមជ្រូក និងទឹកប៊ិច តម្លៃ ១ ០០០ ០០០រៀល ប្រើសម្រាប់រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ
- បណ្ណពណ៌ត្រាវរំលេចផ្កាឈូក និងត្រយ៉ចេក តម្លៃ ១ ២០០ ០០០រៀល ប្រើសម្រាប់រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤ ០០០ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ
- បណ្ណពណ៌ត្រាវរំលេចបៃតងចាស់ និងលឿង តម្លៃ ១ ៦០០ ០០០រៀល ប្រើសម្រាប់រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- បណ្ណពណ៌ត្រាវរំលេចទឹកប៊ិច និងស្លាទុំ តម្លៃ ២ ០០០ ០០០រៀល ប្រើសម្រាប់រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤ ០០០ស.ម³ ឡើងទៅ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ

**២. បណ្ណរាងរង្វង់មូល** (សម្រាប់ប្រើប្រាស់លើម៉ូតូ) ÷ មាត្រដ្ឋាន (អង្កត់ផ្ចិត 73,20mm)

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ **"ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"** **"អគ្គនាយកដ្ឋានពន្ធដារ"** **"ប័ណ្ណបង់ពន្ធលើយានយន្ត"** និងរំលេចឆ្នាំបង់ពន្ធ។ នៅចំកណ្តាលប័ណ្ណរំលេចរូប ប្រាសាទអង្គរវត្ត រាងជាស្រមោល ផ្នែកកណ្តាលស្តាំនៃបណ្ណមានបោះពុម្ព **Hologram Gold Logo** របស់អគ្គនាយកដ្ឋានពន្ធដារ និងខាងឆ្វេងដែលមានតម្លៃបណ្ណ។ នៅផ្នែកខាងក្រោមនៃបណ្ណមាន **Barcode** ដែលមានលេខរៀងបណ្ណ និងលេខ **Barcode** ដូចគ្នា។

**បណ្ណរាងរង្វង់មូលនេះ មាន ៤ពណ៌ គឺ ÷**

- បណ្ណពណ៌ស្វាយ តម្លៃ ៣ ០០០រៀល ប្រើសម្រាប់ទោចក្រយានយន្តទំហំពិស្តុង ដល់ ៧០សម³
- បណ្ណពណ៌ឈាមជ្រូក តម្លៃ ៤ ៥០០រៀល ប្រើសម្រាប់ទោចក្រយានយន្តមានទំហំពិស្តុងលើសពី ៧០សម³ ដល់ ១២៥សម³
- បណ្ណពណ៌ស្លាទុំ តម្លៃ ៧ ៥០០រៀល ប្រើសម្រាប់ទោចក្រយានយន្តមានទំហំពិស្តុងលើសពី ១២៥សម³ ឡើងទៅ
- បណ្ណពណ៌លឿង តម្លៃ ១៥ ០០០រៀល ប្រើសម្រាប់ត្រីចក្រយានយន្ត និងម៉ូតូរ៉ឺម៉កដឹកទំនិញ ឬអ្នកដំណើរ (បំពាក់ដោយម៉ាស៊ីនម៉ូតូ)

**៣. បណ្ណរាងពងក្រពើ** (សម្រាប់ប្រើប្រាស់លើជលយានគ្រប់ប្រភេទ) ÷ មាត្រដ្ឋាន (90,15mm x 70mm)

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ **"ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"** **"អគ្គនាយកដ្ឋានពន្ធដារ"** **"បណ្ណបង់ពន្ធជលយាន"** និងរំលេចឆ្នាំបង់ពន្ធ។ នៅចំកណ្តាលបណ្ណរំលេចរូប **ប្រាសាទអង្គរវត្ត** រាងជាស្រមោល ផ្នែកកណ្តាលស្តាំនៃបណ្ណមានបោះពុម្ព **Hologram Gold Logo** របស់អគ្គនាយកដ្ឋានពន្ធដារ និងខាងឆ្វេងដែលមានតម្លៃបណ្ណ។ នៅផ្នែកខាងក្រោមនៃបណ្ណមាន **Barcode** ដែលមានលេខរៀងបណ្ណ និងលេខ **Barcode** ដូចគ្នា។

**បណ្ណរាងពងក្រពើនេះមាន ១៨ប្រភេទ គឺ ÷**

- បណ្ណពណ៌ផ្ទៃមេឃ តម្លៃ ១០ ០០០រៀល ប្រើសម្រាប់ ÷
  + ទូកនេសាទផ្លូវទន្លេម៉ាស៊ីនចំហៀង (ជើងបង្កង)
  + កាណូតនេសាទផ្លូវទន្លេមានកម្លាំងដល់ ៥០សេះ
  + ទូកនេសាទផ្លូវសមុទ្រមានកម្លាំងដល់ ៩សេះ
  + ទូកនេសាទផ្លូវសមុទ្រម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២សេះ
- បណ្ណពណ៌ទឹកប៊ិច តម្លៃ ១៥ ០០០រៀល ប្រើសម្រាប់ទូកនេសាទផ្លូវសមុទ្រមានកម្លាំងពី ១០សេះ ដល់ ២០សេះ
- បណ្ណពណ៌លឿងខ្ចី តម្លៃ ២០ ០០០រៀល ប្រើសម្រាប់ ÷
  + កប៉ាល់សណ្តោងផ្លូវទន្លេមានកម្លាំងដល់ ៥០សេះ
  + កាណូតនេសាទផ្លូវទន្លេមានកម្លាំងពី ៥០សេះ ដល់ ១០០សេះ
  + ទូកនេសាទផ្លូវសមុទ្រម៉ាស៊ីនចំហៀង (ជើងបង្កង) លើសពី ១២សេះ ដល់ ៥០សេះ
- បណ្ណពណ៌បៃតងខ្ចី តម្លៃ ២៥ ០០០រៀល ប្រើសម្រាប់ទូកនេសាទផ្លូវសមុទ្រមានកម្លាំងលើសពី ២០សេះ ដល់ ៤០សេះ
- បណ្ណពណ៌បៃតង តម្លៃ ៣០ ០០០រៀល ប្រើសម្រាប់ ÷
  + កប៉ាល់សណ្តោងផ្លូវទន្លេមានកម្លាំងលើសពី ៥០សេះ ដល់ ១០០សេះ
  + កាណូតនេសាទផ្លូវទន្លេមានកម្លាំងលើសពី ១០០សេះ ដល់ ១៥០សេះ

- បណ្ណពណ៌បៃតងចាស់ តម្លៃ ៥០ ០០០រៀល ប្រើសម្រាប់ ÷
  + ជលយាន ឬជលយានយន្តផ្លូវទន្លេដឹកទំនិញដល់ ៣តោន
  + កប៉ាល់សណ្តោងផ្លូវទន្លេមានកម្លាំងលើសពី ១០០សេះ ដល់ ១៥០សេះ
  + ទូកនេសាទផ្លូវសមុទ្រម៉ាស៊ីនចំហៀង (ជើងបង្កង) លើសពី ៥០សេះ ឡើងទៅ
  + ទូកនេសាទផ្លូវសមុទ្រមានកម្លាំងលើសពី ៤០សេះ ដល់ ៨០សេះ
- បណ្ណពណ៌ផ្កាឈូកខ្ចី តម្លៃ ៦០ ០០០រៀល ប្រើសម្រាប់កប៉ាល់សណ្តោងផ្លូវទន្លេមានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ
- បណ្ណពណ៌ផ្កាឈូក តម្លៃ ៧០ ០០០រៀល ប្រើសម្រាប់ ទូកនេសាទផ្លូវសមុទ្រមានកម្លាំងលើសពី ៨០សេះ ដល់ ១៥០សេះ
- បណ្ណពណ៌ផ្កាឈូកចាស់ តម្លៃ ១០០ ០០០រៀល ប្រើសម្រាប់
  + ជលយាន ឬជលយានយន្តផ្លូវទន្លេដឹកទំនិញលើសពី ៣តោន ដល់ ១០តោន
  + កប៉ាល់ដឹកអ្នកដំណើរផ្លូវទន្លេមានបណ្តោយដល់ ២០ម៉ែត្រ
  + ទូកដឹកអ្នកដំណើរផ្លូវសមុទ្រមានបណ្តោយដល់ ២០ម៉ែត្រ
  + ទូកនេសាទផ្លូវសមុទ្រមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ
- បណ្ណពណ៌ទឹកក្រូច តម្លៃ ១៥០ ០០០រៀល ប្រើសម្រាប់ ÷
  + ទូកដឹកអ្នកដំណើរផ្លូវសមុទ្រមានបណ្តោយពី ២១ម៉ែត្រ ដល់ ៣០ម៉ែត្រ
  + អូប័រផ្លូវទន្លេ/ សមុទ្រមានកម្លាំងដល់ ២៥សេះ
- បណ្ណពណ៌ក្រហម តម្លៃ ១៨០ ០០០រៀល ប្រើសម្រាប់កប៉ាល់សណ្តោងផ្លូវទន្លេមានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ
- បណ្ណពណ៌លឿង តម្លៃ ២០០ ០០០រៀល ប្រើសម្រាប់ ÷
  + ជលយាន ឬជលយានយន្តផ្លូវទន្លេដឹកទំនិញលើសពី ១០តោន ដល់ ២០តោន
  + កប៉ាល់ដឹកអ្នកដំណើរផ្លូវទន្លេមានបណ្តោយលើសពី ២០ម៉ែត្រ ដល់ ៣០ម៉ែត្រ
  + ទូកដឹកទំនិញផ្លូវសមុទ្រផ្ទុកទំនិញដល់ ១០០តោន
  + កប៉ាល់សណ្តោងផ្លូវសមុទ្រមានកម្លាំងដល់ ២៥០សេះ
  + អូប័រផ្លូវទន្លេ/ សមុទ្រមានកម្លាំងលើសពី ២៥សេះ ដល់ ៤០សេះ
- បណ្ណពណ៌ទឹកក្រូចខ្ចី តម្លៃ ៣០០ ០០០រៀល ប្រើសម្រាប់ ÷
  + ជលយាន ឬជលយានយន្តផ្លូវទន្លេដឹកទំនិញដល់ ២០តោន
  + កប៉ាល់ដឹកអ្នកដំណើរផ្លូវទន្លេមានបណ្តោយលើសពី ៣០ម៉ែត្រ ឡើងទៅ
  + កប៉ាល់សណ្តោងផ្លូវទន្លេមានកម្លាំងលើសពី ២៥០សេះ ឡើងទៅ
  + កប៉ាល់ដឹកទំនិញផ្លូវសមុទ្រផ្ទុកទំនិញលើសពី ១០០តោន ដល់ ១ ០០០តោន
  + កប៉ាល់នេសាទផ្លូវសមុទ្រមានកម្លាំងដល់ ១៥០សេះ
  + អូប័រផ្លូវទន្លេ/ សមុទ្រមានកម្លាំងលើសពី ៤០សេះ ដល់ ៨០សេះ

- បណ្ណពណ៌កាហ្វេខ្ចី តម្លៃ ៤០០ ០០០រៀល ប្រើសម្រាប់ ÷
    + កប៉ាល់នេសាទផ្លូវសមុទ្រមានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ
    + កប៉ាល់សណ្តោងផ្លូវសមុទ្រមានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ
    + អូប័រផ្លូវទន្លេ/សមុទ្រមានកម្លាំងលើសពី ៨០សេះ ដល់ ២០០សេះ
- បណ្ណពណ៌ក្រហមចាស់ តម្លៃ ៥០០ ០០០រៀល ប្រើសម្រាប់អូប័រផ្លូវទន្លេ/សមុទ្រមានកម្លាំងលើសពី ២០០សេះ ឡើងទៅ
- បណ្ណពណ៌ផ្ទៃមេឃខ្ចី តម្លៃ ៦០០ ០០០រៀល ប្រើសម្រាប់ ÷
    + កប៉ាល់នេសាទផ្លូវសមុទ្រមានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ
    + កប៉ាល់សណ្តោងផ្លូវសមុទ្រមានកម្លាំងលើសពី ៥០០សេះ ឡើងទៅ
- បណ្ណពណ៌ទឹកមាស តម្លៃ ៧៥០ ០០០រៀល ប្រើសម្រាប់កប៉ាល់ដឹកទំនិញផ្លូវសមុទ្រផ្ទុកទំនិញលើសពី ១ ០០០តោន ដល់ ២ ០០០តោន
- បណ្ណពណ៌ស្វាយខ្ចី តម្លៃ ១ ២០០ ០០០រៀល ប្រើសម្រាប់ ÷
    + កប៉ាល់ដឹកទំនិញផ្លូវសមុទ្រផ្ទុកទំនិញលើសពី ២ ០០០តោន ឡើងទៅ
    + កប៉ាល់នេសាទផ្លូវសមុទ្រមានកម្លាំងលើសពី ៥០០សេះ ឡើងទៅ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
លេខ...................សហវ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធ II
## ស្តីពី
## ការកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ក្រៅពីរថយន្តទេសចរណ៍

ភ្ជាប់ជាមួយប្រកាសលេខ.១៥៣.សហវ.ប្រក ចុះថ្ងៃទី.២៣.ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ក. មធ្យោបាយដឹកជញ្ជូនទូទៅ ÷**

ឯកតា÷ រៀល

| ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ | កម្រិតប្រាក់ពន្ធ សម្រាប់១ឆ្នាំ/គ្រឿង |
|---|---|
| រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ និងមនុស្ស)] ÷ | |
| - ដល់ ៣តោន | ១៥០ ០០០ |
| - លើសពី ៣តោន ដល់ ១០តោន | ២៥០ ០០០ |
| - លើសពី ១០តោន ដល់ ២០តោន | ៤៥០ ០០០ |
| - លើសពី ២០តោន | ៧៥០ ០០០ |
| រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉ក និងទម្ងន់ផ្ទុក) ÷ | |
| - ដល់ ១០តោន | ២៥០ ០០០ |
| - លើសពី ១០តោន ដល់ ២០តោន | ៤៥០ ០០០ |
| - លើសពី ២០តោន | ៧៥០ ០០០ |
| រថយន្តដឹកអ្នកដំណើរ ÷ | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០ ០០០ |
| - រថយន្តដឹកអ្នកដំណើរចុះមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥កៅអី | ២០០ ០០០ |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥កៅអី | ២៥០ ០០០ |
| ត្រាក់ទ័រ និងគ្រឿងចក្រប្រហាក់ប្រហែល ÷ | |
| - ត្រាក់ទ័រកម្លាំងដល់ ៣៥សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | ៣០ ០០០ |
| - ត្រាក់ទ័រកម្លាំងលើសពី ៣៥សេះ ដល់៦៥សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | ៤០ ០០០ |
| - ត្រាក់ទ័រកម្លាំងលើសពី ៦៥សេះ ដល់៨២សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | ៥០ ០០០ |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

| | |
|---|---|
| ទោចក្រយានយន្ត និងត្រីចក្រយានយន្ត | |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ស.ម$^{៣}$ | ៣ ០០០ |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ៧០ស.ម$^{៣}$ ដល់ ១២៥ស.ម$^{៣}$ | ៤ ៥០០ |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ស.ម$^{៣}$ ឡើងទៅ | ៧ ៥០០ |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ | ១៥ ០០០ |
| ជលយាន ឬជលយានយន្ត ផ្លូវទន្លេ÷ | |
| - ជលយាន ឬជលយានយន្តដឹកទំនិញ÷ | |
| + ដល់ ៣តោន | ៥០ ០០០ |
| + លើសពី ៣តោន ដល់ ១០តោន | ១០០ ០០០ |
| + លើសពី ១០តោន ដល់ ២០តោន | ២០០ ០០០ |
| + លើសពី ២០តោន | ៣០០ ០០០ |
| - ជលយាន ឬជលយានយន្តដឹកអ្នកដំណើរ÷ | |
| + កប៉ាល់មានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| + កប៉ាល់មានបណ្តោយលើសពី ២០ម៉ែត្រ ដល់ ៣០ម៉ែត្រ | ២០០ ០០០ |
| + កប៉ាល់មានបណ្តោយលើសពី ៣០ម៉ែត្រ ឡើងទៅ | ៣០០ ០០០ |
| - ជលយាន ឬជលយានយន្តសណ្តោង÷ | |
| + កប៉ាល់មានកម្លាំងដល់ ៥០សេះ | ២០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ៥០សេះ ដល់ ១០០សេះ | ៣០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ១០០សេះ ដល់ ១៥០សេះ | ៥០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| - ជលយាន ឬជលយានយន្តនេសាទ÷ | |
| + ទូកម៉ាស៊ីនចំហៀង "ជើងបង្កង" | ១០ ០០០ |
| + កាណូតមានកម្លាំងដល់ ៥០សេះ | ១០ ០០០ |
| + កាណូតមានកម្លាំងលើសពី ៥០សេះ ដល់ ១០០សេះ | ២០ ០០០ |
| + កាណូតមានកម្លាំងលើសពី ១០០សេះ ដល់ ១៥០សេះ | ៣០ ០០០ |
| ជលយាន ឬជលយានយន្ត ផ្លូវសមុទ្រ÷ | |
| - ជលយាន ឬជលយានយន្តដឹកអ្នកដំណើរ ÷ | |
| + ទូកមានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| + ទូកមានបណ្តោយពី ២១ម៉ែត្រ ដល់ ៣០ម៉ែត្រ | ១៥០ ០០០ |

| | |
|---|---|
| - ជលយាន ឬជលយានយន្តដឹកទំនិញ ÷ | |
| + ទូកផ្ទុកទំនិញដល់ ១០០តោន | ២០០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ១០០តោន ដល់ ១ ០០០តោន | ៣០០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ១ ០០០តោន ដល់ ២ ០០០តោន | ៧៥០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ២ ០០០តោន ឡើងទៅ | ១ ២០០ ០០០ |
| - ជលយាន ឬជលយានយន្តនេសាទ ÷ | |
| + ទូកម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២សេះ | ១០ ០០០ |
| + ទូកម៉ាស៊ីនចំហៀង (ជើងបង្កង)លើសពី ១២សេះ ដល់ ៥០សេះ | ២០ ០០០ |
| + ទូកម៉ាស៊ីនចំហៀង (ជើងបង្កង) លើសពី ៥០សេះ ឡើងទៅ | ៥០ ០០០ |
| + ទូកមានកម្លាំងដល់ ៩សេះ | ១០ ០០០ |
| + ទូកមានកម្លាំងពី ១០សេះ ដល់ ២០សេះ | ១៥ ០០០ |
| + ទូកមានកម្លាំងលើសពី ២០សេះ ដល់ ៤០សេះ | ២៥ ០០០ |
| + ទូកមានកម្លាំងលើសពី ៤០សេះ ដល់ ៨០សេះ | ៥០ ០០០ |
| + ទូកមានកម្លាំងលើសពី ៨០សេះ ដល់ ១៥០សេះ | ៧០ ០០០ |
| + ទូកមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ | ១០០ ០០០ |
| + កប៉ាល់មានកម្លាំងដល់ ១៥០សេះ | ៣០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ | ៤០០ ០០០ |
| + កប៉ាល់កម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៦០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ១ ២០០ ០០០ |
| - ជលយាន ឬជលយានយន្តសណ្តោង ÷ | |
| + កប៉ាល់មានកម្លាំងដល់ ២៥០សេះ | ២០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៤០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ៦០០ ០០០ |
| អូប៉ផ្លូវទន្លេ/ សមុទ្រ ÷ | |
| - មានកម្លាំងដល់ ២៥សេះ | ១៥០ ០០០ |
| - មានកម្លាំងលើសពី ២៥សេះ ដល់ ៤០សេះ | ២០០ ០០០ |
| - មានកម្លាំងលើសពី ៤០សេះ ដល់ ៨០សេះ | ៣០០ ០០០ |
| - មានកម្លាំងលើសពី ៨០សេះ ដល់ ២០០សេះ | ៤០០ ០០០ |
| - មានកម្លាំងលើសពី ២០០សេះ ឡើងទៅ | ៥០០ ០០០ |

## ២. មធ្យោបាយដឹកជញ្ជូនកែច្នៃផ្សេងទៀត ÷

ឯកតា÷ រៀល

| ល.រ | ប្រភេទ | ចំនួនប្រាក់ពន្ធ |
|---|---|---|
| ១ | រថយន្តដែលបំប្លែងមកពីគោយន្ត និងរថយន្តកែច្នៃកង់បី (បំពាក់ដោយម៉ាស៊ីនរថយន្ត) ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣តោន | ១៥០ ០០០ |
| ២ | រ៉ឺម៉កសណ្ដោងដែលមានភ្លៅ២ កង់៤ | ២៥០ ០០០ |
| ៣ | រ៉ឺម៉កសណ្ដោងដែលមានភ្លៅ២ កង់៨ | ៤៥០ ០០០ |
| ៤ | រថយន្តដឹកទំនិញដែលមានភ្លៅ៣ កង់៦ | ៤៥០ ០០០ |
| ៥ | រថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ៣ កង់១០ | ៧៥០ ០០០ |

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....................សហវ

# ឧបសម្ព័ន្ធ III

## ស្តីពី

## ការកំណត់ប្រាក់ពន្ធតាមទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍

ភ្ជាប់ជាមួយប្រកាសលេខ...............ប្រក.សហវ.អពដ ចុះថ្ងៃទី......... ខែ......... ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឯកតា ÷ រៀល

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម³ "CC" | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ | លើសពី៥ឆ្នាំ ដល់១០ឆ្នាំ | លើសពី ១០ឆ្នាំ |
| ១ | ដល់ ១ ៥០០ស.ម³ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| ២ | លើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ | ២០០ ០០០ | ១៥០ ០០០ | ១០០ ០០០ |
| ៣ | លើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ | ៦០០ ០០០ | ៤០០ ០០០ | ២៥០ ០០០ |
| ៤ | លើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |
| ៥ | លើសពី ៤ ០០០ស.ម³ ឡើងទៅ | ២ ០០០ ០០០ | ១ ២០០ ០០០ | ៨០០ ០០០ |

រាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798